***The International Programme on the Elimination of Child Labour***

# យល់ដឹងអំពីអង្គការ ILO IPEC និង ពលកម្មកុមារ

# អង្គការពលកម្មអន្តរជាតិ ILO

- អង្គការពលកម្មអន្តរជាតិ ត្រូវបានបង្កើតឡើងនៅឆ្នាំ 1919 បន្ទាប់ពីសង្គ្រាមលោកលើកទី I
- អង្គការពលកម្មអន្តរជាតិ គឺជាស្ថាប័នជំនាញមួយរបស់អង្គការសហប្រជាជាតិ
- អង្គការពលកម្មអន្តរជាតិ គឺជាស្ថាប័នអង្គការសហប្រជាជាតិចាស់ជាងគេបំផុត ។

# អង្គការពលកម្មអន្តរជាតិ ILO

- រដ្ឋាភិបាល សមាគមនិយោជក និងសហជីពនៃប្រទេសជាសមាជិក គឺជាដៃគូរបស់ អង្គការពលកម្មអន្តរជាតិ ILO
- សមាគមនិយោជក និងសហជីព ត្រូវបានគេហៅថា ជាដៃគូសង្គម របស់អង្គការពលកម្មអន្តរជាតិ ILO
- ដូច្នេះ អង្គការពលកម្មអន្តរជាតិ ILO គឺជាស្ថាប័នត្រីភាគី តែមួយគត់ របស់អង្គការសហប្រជាជាតិ ។

# អង្គការពលកម្មអន្តរជាតិ ILO

- អង្គការពលកម្មអន្តរជាតិ ILO មានប្រទេសជាសមាជិក ចំនួន ១៨១ ប្រទេស
- សន្និសីទការងារអន្តរជាតិ ត្រូវបានចូលរួមដោយ តំណាងមកពីរដ្ឋាភិបាល សមាគមនិយោជក និងសហជីព នៃប្រទេសជាសមាជិក ហើយពួកគេ គឺជា ក្រុមប្រឹក្សារៀបចំគោលនយោបាយដ៏សំខាន់របស់អង្គការ ILO
- សន្និសីទការងារអន្តរជាតិ ត្រូវបានរៀបចំធ្វើឡើង ជារៀងរាល់ឆ្នាំ នៅខែមិថុនា ។

# អាណត្តរបស់អង្គការ ILO

- នៅក្នុងប្រព័ន្ធរបស់ UN, អង្គការ ILO មានអណត្ត លើបញ្ហាទាំងអស់ដែលពាក់ព័ន្ធនឹងការងារ និងទំនាក់ទំនង រវាងនិយោជក និងសហជីព ។
- អង្គការ ILO បំពេញអណត្តរបស់ខ្លួន តាមរយៈការអនុម័តអនុសញ្ញាអន្តរជាតិ និងអនុសាសន៍នានា ។
- អនុសញ្ញារបស់ អង្គការ ILO នៅពេលដែលបានផ្តល់សច្ចាប័នដោយប្រទេសជាសមាជិក នឹងក្លាយជាច្បាប់អន្តរជាតិ ។

# អាណត្តរបស់អង្គការ ILO

- អង្គការ ILO ធ្វើការដើម្បីលើកកំពស់ ***ការងារសមរម្យ*** –
- ***ការងារសមរម្យ*** : ការងារប្រកបដោយផលិតភាព ក្នុងលក្ខខ័ណ្ឌសេរីភាព សមភាព សន្តិសុខ និងសេចក្តីថ្លៃថ្នូរជាមនុស្ស ។
- ការងារសមរម្យ គឺជាបញ្ញត្តមួយទូលាយ រួមមាន :
  - សិទ្ធិមូលដ្ឋាន នៅនឹងកន្លែងការងារ
  - ជីវភាពគ្រប់គ្រាន់ (ការងារកាន់តែច្រើន និងល្អប្រសើរ)
  - កិច្ចការពារសង្គម (ការងារមានសុវត្ថិភាព, មានការឧបត្ថម្ភគាំទ្រនៅពេលមានជម្ងឺ)
  - មានការពិគ្រោះយោបល់ពីដៃគូរសង្គម (រវាងនិយោជក សហជីព និងរដ្ឋាភិបាល)

# អង្គការ ILO និង ពលកម្មកុមារ

- នៅក្នុង UN អង្គការ ILO ក៏មានអាណត្តលើពលកម្មកុមារដែរ ។
- អង្គការ ILO បំពេញអាណត្តលើពលកម្មកុមារ តាមរយៈ
  - ការអនុម័តលើអនុសញ្ញា និងអនុសាសន៍ ស្តីពីពលកម្មកុមារ
  - ការផ្តល់ប្រឹក្សាបច្ចេកទេស និងគាំទ្រដល់ប្រទេសជាសមាជិក (កម្មវិធីអន្តរជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ ~ IPEC)

# អង្គការ ILO និង ពលកម្មកុមារ

- អនុសញ្ញាទី ១ ដែលបានអនុម័តដោយអង្គការ ILO ក្នុងឆ្នាំ ១៩១៩ គឺអនុសញ្ញា No. 5 ស្តីពី ការហាមប្រាមការប្រើប្រាស់កុមារនៅក្នុងរោងចក្រ និងសហគ្រាសឧស្សាហកម្ម ។

# អនុសញ្ញាលេខ 138

- ក្នុងឆ្នាំ 1973 សន្និសីទការងារអន្តរជាតិ បានអនុម័តអនុសញ្ញាដ៏ទូលំទូលាយមួយស្តីពីពលកម្មកុមារដែលគ្របដណ្តប់គ្រប់វិស័យ និងប្រភេទការងារទាំងអស់ ។
- អនុសញ្ញាលេខ ១៣៨ នេះ បានកំណត់អាយុអប្បរិមាដើម្បីចូលធ្វើការ ហើយហាមឃាត់កុមារអាយុក្រោមកំរិតនេះមិនឱ្យធ្វើការក្នុងទំរង់ការងារណាឡើយ ។

# អនុសញ្ញាលេខ 138

- អនុសញ្ញាលេខ ១៣៨ ចែកការងារទាំងអស់ជា ៣ ក្រុម ៖
  - ការងារស្រាល Light
  - ការងារធម្មតា Normal
  - ការងារប្រកបដោយគ្រោះថ្នាក់ Hazardous

ហើយបានកំណត់អាយុអប្បបរិមាខុសៗគ្នា ដើម្បីឱ្យចូលធ្វើការប្រភេទ ខុសៗគ្នា ទាំង ៣

# អនុសញ្ញាលេខ 138

- អាយុអប្បរិមាដែលត្រូវបានកំណត់ឱ្យចូលធ្វើការងារ ដូចខាងក្រោម :
  - ការងារស្រាល Light ១៣ ឆ្នាំ
  - ការងារធម្មតា Normal ១៥ ឆ្នាំ
  - ការងារប្រកបដោយគ្រោះថ្នាក់ Hazardous ១៨ ឆ្នាំ

# អនុសញ្ញាលេខ 138

- ទោះជាយ៉ាងណាក៏ដោយ ប្រទេសកំពុងអភិវឌ្ឍន៍ ដូចជាប្រទេសកម្ពុជា អនុសញ្ញាលេខ ១៣៨ ផ្តល់ឱ្យអាយុអប្បបរិមាទាបជាងខ្លះ ផងដែរ :
  - ការងារធម្មតា Normal ១៤ ឆ្នាំ
  - ការងារស្រាល Light ១២ ឆ្នាំ
  - ការងារប្រកបដោយគ្រោះថ្នាក់ Hazardous ១៦ ឆ្នាំ

# អនុសញ្ញាលេខ 138 និង រាជរដ្ឋាភិបាលកម្ពុជា

កម្ពុជា បានផ្តល់សច្ចាប័ន និងចូលជាធរមាន អនុសញ្ញាលេខ 138 នៅថ្ងៃទី ២៣ ខែសីហា ឆ្នាំ១៩៩៩ ។

# អនុសញ្ញាលេខ 182

- ខណៈពេលដែលអនុសញ្ញាលេខ ១៣៨ តម្រូវឱ្យលុបបំបាត់រាល់ទម្រង់ទាំងអស់នៃពលកម្មកុមារ គោលដៅនេះ ទំនងជាទាមទាររយៈពេលមួយវែង ។
- ប៉ុន្តែ បច្ចុប្បន្ន មានទំរង់នៃពលកម្មកុមារខ្លះ មិនអាចបណ្តោយយូរបានទេ ហើយត្រូវតែលុបបំបាត់ជាបន្ទាន់ នោះគឺ ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។
- អនុសញ្ញាលេខ ១៨២ មានគោលបំណងលុបបំបាត់ជាបន្ទាន់ ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ។

# អនុសញ្ញាលេខ 182 :

# អនុសញ្ញាដែលត្រូវបានផ្តល់សច្ចាប័នលឿនបំផុត

- អនុសញ្ញាលេខ 182 ត្រូវបានអនុម័តក្នុងឆ្នាំ 1999.
- ជាអនុសញ្ញាលើកទី ១ របស់ ILO ដែលត្រូវបានអនុម័តជាឯកច្ឆ័ន្ទ ដោយប្រទេសជាសមាជិកទាំងអស់របស់អង្គការ ILO ។
- រហូតមកទល់ពេលនេះ មានប្រទេសជាង ១៥០ នៃប្រទេស ១៨១ ដែលជាសមាជិករបស់ ILO បានផ្តល់សច្ចាប័នលើអនុសញ្ញានេះ ។

# ប្រភេទទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ក្រោមអនុសញ្ញាលេខ 182

អនុសញ្ញាលេខ 182 កំណត់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារជា ៤ ប្រភេទ :

- រាល់ទំរង់ទាសភាព ការជួញដូរកុមារ ការធ្វើការដោះបំណុល ការងារដោយបង្ខំ និងជំលោះប្រដាប់អាវុធ
- បេស្យាចារ និងការថតរូបអាសអាភាសន៍
- សកម្មភាពខុសច្បាប់ ដូចជាផលិត ឬការជួញដូរគ្រឿងញៀន
- ទំរង់ការងារផ្សេងៗទៀតដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព សុវត្ថិភាព សីលធម៌ និងការអប់រំរបស់កុមារ ។

# អាយុអប្បបរិមាក្រោមអនុសញ្ញាលេខ 182

- អនុលោមតាមអនុសញ្ញាលេខ ១៨២ កុមារអាយុក្រោម ១៨ ឆ្នាំ មិនអនុញ្ញាតឱ្យធ្វើការនៅក្នុងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ៤ ប្រភេទខាងលើនេះឡើយ ។
- លើកលែងប្រភេទទី ៤ ករណីនៃពលកម្មកុមារប្រកបដោយគ្រោះថ្នាក់ រដ្ឋាភិបាលនៃប្រទេសមួយ អាចបន្ថយអាយុត្រឹម ១៦ ឆ្នាំ ប្រសិនបើ លក្ខខ័ណ្ឌការងារសមស្របមិនប៉ះពាល់ដល់សុវត្ថិភាព និងសុខភាព របស់កុមារ ។

# ភាតព្វកិច្ចរបស់ប្រទេសក្រោមអនុសញ្ញាលេខ 182

ប្រទេសដែលផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២

ត្រូវចាត់វិធានការមានពេលកំណត់

ដើម្បីលុបបំបាត់ជាបន្ទាន់ទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

# ភាតព្វកិច្ចរបស់ប្រទេសក្រោមអនុសញ្ញាលេខ 182

ប្រទេសដែលផ្តល់សច្ចាប័នលើអនុសញ្ញាលេខ ១៨២ ត្រូវចាត់វិធានការមានពេលកំណត់ និងប្រសិទ្ធភាពដើម្បី

- ទប់ស្កាត់ការចូលរួមរបស់កុមារក្នុងទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ
- ផ្តល់ជំនួយផ្ទាល់ដើម្បីដកហូតកុមារចេញពីទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ស្តារ លទ្ធភាពពលកម្ម និងធ្វើសមាហរណកម្មពួកគេនៅក្នុងសង្គម និងធានាឱ្យពួកគេ មានលទ្ធភាពទទួលបានការអប់រំដោយសេរី និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមលទ្ធភាពដែលអាចធ្វើទៅបាន ។
- កំណត់ និងជួយដល់កុមារក្នុងភាពងាយរងគ្រោះពិសេស ។
- យកចិត្តទុកដាក់ចំពោះស្ថានភាពពិសេសរបស់កុមារី ។

# អនុសញ្ញាលេខ 182 និង រាជរដ្ឋាភិបាលកម្ពុជា

កម្ពុជា បានផ្តល់សច្ចាប័ន និងចូលជាធរមាន អនុសញ្ញាលេខ 182 នៅថ្ងៃទី ២៤ ខែតុលា ឆ្នាំ២០០៥ ។

# កម្ពុជា  គ្មានពលកម្មកុមារ

# សូមអរគុណ